ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៤៧០ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៧

# ប្រកាស
## ស្តីពី
## អត្រាបុព្វលាភនៃការធានារ៉ាប់រងអគ្គីភ័យ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ស្តីពីការធានារ៉ាប់រង

- បានឃើញលក្ខន្តិកៈ ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៥ របស់សមាគមធានារ៉ាប់រងទូទៅកម្ពុជា

## សម្រេច

### ប្រការ ១ : បទប្បញ្ញត្តិទូទៅ

ដោយអនុលោមតាមមាត្រាទី ៨៩ នៃអនុក្រឹត្យស្តីពីការធានារ៉ាប់រង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានឯកភាពជាមួយសមាគមធានារ៉ាប់រងទូទៅកម្ពុជា «សធទក» លើអត្រាបុព្វលាភអប្បបរិមានៃការធានារ៉ាប់រងអគ្គិភ័យ ដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ ។ រាល់ការផ្លាស់ប្តូរទាំង-ឡាយ ដែលនាំឱ្យមានការកែប្រែតារាងអត្រាបុព្វលាភនេះ ត្រូវមានការយល់ព្រមជាមុន ជាលាយលក្ខអក្សរ ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

គ្រប់សមាជិកទាំងអស់របស់សមាគមធានារ៉ាប់រងទូទៅកម្ពុជា ត្រូវអនុវត្តតាមតារាងអត្រាបុព្វលាភធានារ៉ាប់រងនេះ ដោយអនុលោមទៅតាមមាត្រា ៨ក នៃលក្ខន្តិកៈរបស់សមាគមធានារ៉ាប់រងទូទៅ នេះ ។ សមាគមធានារ៉ាប់រងទូទៅកម្ពុជា មានភារៈទទួលខុសត្រូវ និង ពង្រឹងការអនុវត្ត នូវអត្រាបុព្វលាភធានារ៉ាប់រងអគ្គិភ័យនេះ ។

### ប្រការ ២ : ការរំលោភលើអត្រាបុព្វលាភ

ក្នុងករណីដែលសមាគមពិនិត្យឃើញថា មានការរំលោភលើអត្រាបុព្វលាភ ដែលបានអនុម័តរួចនេះ ពិតប្រាកដមែន ក្រុមប្រឹក្សាវិន័យរបស់សមាគម នឹងពិចារណាក្នុងការដាក់ពិន័យទៅលើសមាជិកណា ដែលបានរំលោភ តាមកំរិតដូចខាងក្រោមនេះ :

ក- ចំពោះការរំលោភលើកទី ១ សមាជិកដែលបានប្រព្រឹត្តនូវការរំលោភនេះ នឹងត្រូវបានកោះហៅ ឱ្យមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាវិន័យ ដើម្បីធ្វើការពន្យល់ និង ធ្វើការកែតម្រូវជាបន្ទាន់មួយ សម្រាប់ភាពដែលមិនប្រក្រតី ។

ខ- ការផាកពិន័យជាទឹកប្រាក់ក្នុងចន្លោះ ពី ១.០០០ (មួយពាន់) ដុល្លារអាមេរិក ទៅ ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក នឹងអនុវត្តលើសមាជិកណា ដែលបានរំលោភលើអត្រាបុព្វលាភនេះ ជាលើកទី ២ ។

គ- ក្នុងករណីមានការរំលោភជាលើកទី ៣ ដោយមិនរាងចាល សមាជិកនោះ នឹងត្រូវទទួលការផាកពិន័យជាទឹកប្រាក់ក្នុងចន្លោះពី ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក ទៅ ១០.០០០ (ដប់ពាន់) ដុល្លារអាមេរិក ។

ឃ- ក្រុមប្រឹក្សាវិន័យនឹងបង្វែរការដាក់ទណ្ឌកម្មពិន័យនេះ ទៅឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងករណីដែលមិនរាងចាល ដោយប្រព្រឹត្តរំលោភលើបញ្ញត្តិនៃប្រកាសនេះ ចាប់ពីលើកទី ៤ ឡើងទៅ ។

ប្រាក់ពិន័យដែលទទួលបានសំរាប់ចំនុច «ខ» និង «គ» ត្រូវបង់ដោយផ្ទាល់ទៅសមាគមធានារ៉ាប់រងទូទៅកម្ពុជា ។

## ប្រការ ៣ : នីតិវិធីដាក់ពិន័យ

រាល់ការរំលោភទាំងឡាយ ទៅលើតារាងអត្រាបុព្វលាភ នឹងត្រូវដោះស្រាយដោយសមាគមធានារ៉ាប់រងទូទៅកម្ពុជា ដោយផ្អែកទៅលើមាត្រា ១៨ នៃលក្ខន្តិកៈរបស់សមាគម ។

ក្រុមប្រឹក្សាវិន័យដែលនឹងត្រូវស៊ើបអង្កេតអំពីការរំលោភទៅលើតារាងអត្រាបុព្វលាភនេះ ត្រូវមាន សមាជិកយ៉ាងតិច ៣ រូប ដែល ១ រូប ក្នុងចំណោមនោះ គឺជាតំណាងមកពីវិទ្យាស្ថានកម្ពុជា សំរាប់គណនេយ្យករសាធារណៈ និងសវនករ ។ ប្រធានក្រុមប្រឹក្សាវិន័យ គឺជាប្រធានសមាគមធានារ៉ាប់រងទូទៅកម្ពុជា ឬតំណាងដែលទទួលការតែងតាំងពីប្រធានសមាគមនេះ ។

## ប្រការ ៤ : ការចូលជាធរមាន

ប្រកាសនេះនឹងចូលជាធរមាន បន្ទាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធ ប្រធានសមាគមធានារ៉ាប់រងទូទៅកម្ពុជា ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ដែលជាសមាជិកសមាគម ត្រូវអនុវត្ត និង ប្រតិបត្តិតាមខ្លឹមសារនៃប្រកាសនេះ ឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

<u>ចម្លងជូន</u> :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ឯកសារ - កាលប្បវត្តិ